# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....០០៦...............សហវ.ទកម

ថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ២០២០

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា ៥ នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចតទៅ÷

## ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២០ តរៀងទៅ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែនីមួយៗយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

តារាងអត្រាកំណត់តាមថ្នាក់ថ្មីមានដូចខាងក្រោម÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ៣០០ ០០០៛ | 0% |
| ពី | ១ ៣០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

## ២. ទាយជ្ជទានសម្រាប់សហព័ន្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ន្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥០ ០០០រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១ ៣០០ ០០១ រៀល ដល់ ២ ០០០ ០០០ រៀល (ប្រមាណពី ៣២៥ ទៅ ៥០០ ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## ៣.ការគណនាពន្ធលើប្រាក់បៀវត្ស

យោងតាមមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសនជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយក ចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ ដោយឡែក ចំពោះកម្មករ និយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួល បានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្ត កាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋាន គិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ៣០០ ០០០ រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ៣០០ ០០០៛ | ០% | ០ ៛ |
| ពី | ១ ៣០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% | ៦៥ ០០០ ៛ |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% | ១៦៥ ០០០ ៛ |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% | ៥៩០ ០០០ ៛ |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% | ១ ២១៥ ០០០ ៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស (ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ (លបព)

<u>កំណត់សម្គាល់÷</u>

ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភ ដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១÷** កម្មករនិយោជិត រោងចក្រ សហគ្រាស ម្នាក់មានប្រាក់បៀវត្ស ១ ៩០០ ០០០ រៀល ដែលក្នុងនោះមាន ប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរនិងថ្លៃបាយសរុបចំនួន ១០០ ០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ១ ៩០០ ០០០៛ - ១០០ ០០០៛ = ១ ៨០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ៥%)

លបព = ៦៥ ០០០៛

ពបវ = (១ ៨០០ ០០០៛ x ៥%) - ៦៥ ០០០៛ = <u>២៥ ០០០៛</u>

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x ៤ = ៦០០ ០០០៛

មពបវ = ១ ៩០០ ០០០៛ - ១០០ ០០០៛ - ៦០០ ០០០៛ = ១ ២០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ០%)

លបព = ០៛

ពបវ = (១ ២០០ ០០០៛ x ០%) - ០៛ = <u>០៛</u>

**ឧទាហរណ៍ទី២៖** អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់មានប្រាក់បៀវត្ស ៨ ៧០០ ០០០រៀល

**ក. ករណីនៅលីវ**

មពបវ = ៨ ៧០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១៥%)

លបព = ៥៩០ ០០០៛

ពបវ = (៨ ៧០០ ០០០៛ x ១៥%) - ៥៩០ ០០០៛ = <u>៧១៥ ០០០៛</u>

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x ៤ = ៦០០ ០០០៛

មពបវ = ៨ ៧០០ ០០០៛ - ៦០០ ០០០៛ = ៨ ១០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១០%)

លបព = ១៦៥ ០០០៛

ពបវ = (៨ ១០០ ០០០៛ x ១០%) - ១៦៥ ០០០៛ = <u>៦៤៥ ០០០៛</u>

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានភារកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ-កាលប្បវត្តិ